## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៨២/១៧ ក.ប/ស.ជ.ណ.ក.ក

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រារព្ធទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារ
# ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៧

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់គ្រប់ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត និយោជក សហព័ន្ធសហជីព ព្រមទាំងកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ឲ្យបានជ្រាបថា **ទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ** ត្រូវបានរៀបចំឡើងនៅថ្ងៃទី២៨ ខែមេសា ជារៀងរាល់ឆ្នាំដោយប្រទេសជាសមាជិក នៃអង្គការអន្តរជាតិខាងការងារ ក្នុងគោលបំណង ដើម្បីលើកកម្ពស់សុខភាព និងសុវត្ថិភាពការងារ និងរំលឹកដល់វិញ្ញាណក្ខន្ធកម្មករនិយោជិតដែលបានបាត់បង់ជីវិតដោយសារគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈនៅលើពិភពលោក។ នេះជាឆ្នាំទី១២ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រារព្ធទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ក្រោមប្រធានបទ "**បង្កើនសុក្រឹត្យភាពក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យសុខភាព និងសុវត្ថិភាពការងារ**"។

ដើម្បីរួមចំណែកក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់សុខភាព និងសុវត្ថិភាពការងារ និងបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈជាយថាហេតុដល់បងប្អូនកម្មករនិយោជិត សូមលោក លោកស្រីប្រធាន ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានបោះទីតាំងនៅតាមបណ្តារាជធានី-ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំប្រារព្ធទិវានេះឲ្យបានអធិកអធមនៅតាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួន និងចងបដាពាក្យស្លោកមួយចំនួននៅតាមរបងខាងមុខសហគ្រាស គ្រឹះស្ថាន ដើម្បីចូលរួមអបអរសាទរទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ មានដូចខាងក្រោម៖

១. អបអរសាទរទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ
២. បង្កើនសុក្រឹត្យភាពក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យសុខភាព និងសុវត្ថិភាពការងារ
៣. ត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅគ្រប់កន្លែងធ្វើការ
៤. សុវត្ថិភាពការងារ ជាអាទិភាពទីមួយរបស់យើង
៥. រួមគ្នាកសាងវប្បធម៌ នៃការបង្ការសុខភាព និងសុវត្ថិភាពការងារ
៦. រួមគ្នាការពារសិទ្ធិការងារ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសការងារប្រកបដោយសុវត្ថិភាព
៧. យើងរួមគ្នាតត់ត្រាទុក និងជូនដំណឹងអំពីគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ
៨. ចូរប្រើប្រាស់ទិន្នន័យអំពី គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៩. យើងរួមគ្នាជំរុញអោយមានប្រព័ន្ធថ្នាក់ជាតិសំរាប់រាយការណ៍ ការប្រមូលលទិន្នន័យ និងការវិភាគអំពី គ្រោះថ្នាក់ និងជំងឺវិជ្ជាជីវៈ
១០. ចូរតាមមើលជាប្រចាំអំពីវិធានការណ៍បង្ការនានា ដើម្បីកុំអោយមានបាតុភូតមហន្តរាយនៅកន្លែងការងារ
១១. មានសុវត្ថិភាពការងារគឺគ្មានគ្រោះថ្នាក់ការងារ
១២. ភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការជាក្តីកង្វល់របស់យើងទាំងអស់គ្នា
១៣. ធានាឲ្យគ្រប់កន្លែងការងារមានសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា
១៤. កន្លែងការងារប្រកបដោយសុខភាព និងសុវត្ថិភាពល្អ នាំឲ្យកើនផលិតភាព និងប្រាក់ចំណូល
១៥. គន្លឹះឈានទៅរកសុវត្ថិភាពការងារ គឺស្ថិតនៅក្នុងដៃលោកអ្នក
១៦. វិធានសុវត្ថិភាពការងារជាមធ្យោបាយប្រសើរបំផុតនៅកន្លែងធ្វើការ
១៧. និយោជកត្រូវផ្តល់សម្ភារការពារបុគ្គលដល់កម្មករនិយោជិត
១៨. រួមគ្នាកាត់បន្ថយគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ
១៩. ការឈឺចាប់កើតចេញពីកន្លែងធ្វើការដែលគ្មានសុវត្ថិភាព
២០. ជីវិតរបស់ខ្ញុំ ការងាររបស់ខ្ញុំ និងការងារប្រកបដោយសុវត្ថិភាពរបស់ខ្ញុំ
២១. ការងារសមរម្យ គឺជាការងារប្រកបដោយសុវត្ថិភាព
២២. សុវត្ថិភាពការងារជាជម្រើសដែលអ្នកត្រូវជ្រើសរើសជាចាំបាច់
២៣. រួមគ្នាការពារហានិភ័យដែលកើតឡើងដោយភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការ
២៤. បង្ការ និងទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ និងលប់បំបាត់ការរើសអើងនៅកន្លែងការងារ
២៥. គ្រឿងញៀនបំផ្លាញសុខភាព និងអនាគត របស់យើង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត សមាគមនិយោជក និងនិយោជក ព្រមទាំងសហព័ន្ធសហជីពនៃសហគ្រាសគ្រឹះស្ថានទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
- ឯកសារ-កាលប្បវត្តិ